**ព្រះរាជាណាចក្រកម្ពុជា**
ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងមុខងារសាធារណៈ**

# សារលិខិតជូនពរ

**សូមគោរពជូន**
**សម្ដេចធម្មវិសុទ្ធវង្សា សៅ ទី ហេង សំរិន**

**សម្ដេចធម្មវិសុទ្ធវង្សា ជាទីគោរពដ៏ខ្ពង់ខ្ពស់!**

ក្នុងឱកាសដ៏បវរសួស្ដី សិរីមង្គលមហាប្រសើរ នៃពិធីចម្រើនជន្មាយុគម្រប់ ៨៥ឆ្នាំ ឈានចូល ៨៦ឆ្នាំ របស់ **សម្ដេចធម្មវិសុទ្ធវង្សា** នៅថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ២០២៣នេះ យើងខ្ញុំជាថ្នាក់ដឹកនាំ និងមន្ត្រីរាជការ នៃក្រសួងមុខងារសាធារណៈ សូមសម្ដែងនូវអំណរសាទរយ៉ាងជ្រាលជ្រៅ ជូនចំពោះ **សម្ដេចធម្មវិសុទ្ធវង្សា** សូមសម្បូរសមប្រកបដោយសុខភាពល្អបរិបូរណ៍ កាយពលមាំមួន បញ្ញាញាណវាងវៃ និងមានជន្មាយុយឺនយូរ។

ឆ្លៀតក្នុងឱកាសដ៏វិសេសវិសាលថ្លៃថ្លានេះ យើងខ្ញុំទាំងអស់គ្នា សូមអនុញ្ញាតសម្ដែងនូវការកោតសរសើរ ដ៏ស្មោះចំពោះទឹកចិត្តដ៏ថ្លៃថ្លា និងសកម្មភាពដ៏ឧត្ដុង្គឧត្ដមរបស់ **សម្ដេចធម្មវិសុទ្ធវង្សា** ដែលជានិច្ចកាល តែងតែរួមដំណើរជម្រុញលើកទឹកចិត្តនិងគាំទ្រ **សម្ដេចអគ្គមហាពញាចក្រី ហេង សំរិន** ក្នុងបេសកកម្ម ដឹកនាំស្ថាប័ននីតិប្បញ្ញត្តិ ឱ្យបានល្អប្រសើរជូនប្រទេសជាតិ មានសន្តិភាព និងស្ថិរភាព ក៏ដូចជារួមចំណែកយ៉ាង សំខាន់ដល់ការពង្រឹងនីតិរដ្ឋ លទ្ធិប្រជាធិបតេយ្យសេរីពហុបក្ស និងការគោរពសិទ្ធិមនុស្សនៅព្រះរាជាណាចក្រ កម្ពុជា។ **សម្ដេច** ជាឧត្ដមភរិយា ជាមាតា ជាជីដូន និងជាជីដូនទួត ប្រកបដោយព្រហ្មវិហារធម៌ គុណធម៌ និង ជាគំរូដ៏ប្រពៃសម្រាប់ស្ត្រីគ្រប់រូបគោរពនិងដើរតាមមាគ៌ានេះ។

ជាថ្មីម្ដងទៀត យើងខ្ញុំទាំងអស់គ្នា សូមបួងសួងដល់គុណបុណ្យព្រះរតនត្រ័យ និងវត្ថុស័ក្តិសិទ្ធិទាំងអស់ ក្នុងលោក សូមប្រោសប្រទានជូន **សម្ដេចធម្មវិសុទ្ធវង្សា សៅ ទី ហេង សំរិន និងសម្ដេច អគ្គមហាពញាចក្រី ហេង សំរិន ព្រមទាំង បុត្រា បុត្រី ចៅប្រុស ចៅស្រី** សូមមានសុខភាពល្អ បរិបូរណ៍ និងទទួលបានព្រះពុទ្ធពរទាំងបួនប្រការគឺ អាយុ វណ្ណៈ សុខៈ និងពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

សូម **សម្ដេចធម្មវិសុទ្ធវង្សា** មេត្តាទទួលនូវសេចក្ដីគោរពដ៏ជ្រាលជ្រៅ និងខ្ពង់ខ្ពស់បំផុតពីយើងខ្ញុំ ទាំងអស់គ្នា៕

ថ្ងៃ អង្គារ ២កើត ខែផល្គុន ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦
រាជធានីភ្នំពេញ ថ្ងៃទី ២១ ខែ កុម្ភៈ ឆ្នាំ២០២៣
**តំណាងថ្នាក់ដឹកនាំនិងមន្ត្រីរាជការនៃក្រសួងមុខងារសាធារណៈ**
**រដ្ឋមន្ត្រី**

**ហ៊ុំ សុខា**

ផ្លូវវិត្ដអង្គតាមិញ ភូមិគោកចំបក់ សង្កាត់ចោមចៅ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ/ទូរសារ : +៨៥៥-២៣-៨៦៦៥០១/+៨៥៥-២៣-៨៦៦៥០៥ | គេហទំព័រ : http://www.mcs.gov.kh